ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧៤ អយក.ប្រក

## ប្រកាស
## ស្ដីពី
## ការបង្កើតការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌព្រែកព្នៅ នៃមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨៧៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការបង្កើតខណ្ឌព្រែកព្នៅនៃរាជធានីភ្នំពេញ និងការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខណ្ឌពោធិ៍សែនជ័យ និងខណ្ឌសែនសុខនៃរាជធានីភ្នំពេញ

## សម្រេច

**ប្រការ១ _**

ត្រូវបានបង្កើតការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌព្រែកព្នៅស្ថិតក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ។

**ប្រការ២ _**

រចនាសម្ព័ន្ធ មុខងារ ភារកិច្ច និងភារកិច្ចរបស់ការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌព្រែកព្នៅ ត្រូវអនុវត្តឱ្យស្របតាមសេចក្ដីណែនាំលេខ ៣៧៦៧ អយក.សណន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ : (៨៥៥-២៣) ២១០ ១៤៣ /២១៧ ២៥៣ /៨២៦ ៥៥១ ទូរសារ : (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ៣.-**

ការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌព្រែកព្នៅ ដឹកនាំដោយប្រធាន១រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ស្របតាមនិយាម និងត្រូវតែងតាំងដោយដីការបស់អភិបាលរាជធានីភ្នំពេញស្របតាមនីតិវិធីជាធរមាន។

ការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌព្រែកព្នៅ ត្រូវមានចំនួនបុគ្គលិកអប់រំបម្រើការងារស្របតាមនិយាម។

**ប្រការ៤.-**

ការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌព្រែកព្នៅមានវិសាលភាពគ្របដណ្តប់លើការងារអប់រំ យុវជន និងកីឡាក្នុងសង្កាត់ព្រែកព្នៅ សង្កាត់ពញាពន់ សង្កាត់សំរោង សង្កាត់គោករកា និងសង្កាត់ពន្សាំង។

**ប្រការ៥.-**

បុគ្គលិកអប់រំ ចលនទ្រព្យ អចលនទ្រព្យ ថវិកាគ្រប់ជំពូកនិងគ្រប់គម្រោង និងសាលារៀនដែលមានទីតាំងស្ថិតនៅក្នុងសង្កាត់ព្រែកព្នៅ សង្កាត់ពញាពន់ និងសង្កាត់សំរោង នៃខណ្ឌសែនសុខ និងសង្កាត់គោករកា និងសង្កាត់ពន្សាំង នៃខណ្ឌពោធិ៍សែនជ័យត្រូវផ្ទេរឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌព្រែកព្នៅ។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៤

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**អន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានីភ្នំពេញ

  «ដើម្បីជូនជ្រាប»
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូច ប្រការ៧

  «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ នា.និតិកម្ម